ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ០៦៣/១៦ គ.ជ.ប.ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

---

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញបទបញ្ជាផ្ទៃក្នុងលេខ ១១៩៨/១២ គ.ជ.ប ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ។

## សម្រេច

**ប្រការ១.-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបំពេញតួនាទីជាតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់រៀងៗខ្លួន ។

**ប្រការ២.-**

ក្នុងការអនុវត្តភារកិច្ចខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ បទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

**ប្រការ៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំក្រុមចុះឈ្មោះបោះឆ្នោត ដែលត្រូវបានបង្កើតឡើងដោយ គ.ជ.ប ឱ្យអនុវត្តបានត្រឹមត្រូវតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ បទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប ។ ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្រុមចុះឈ្មោះបោះឆ្នោតត្រូវធ្វើរបាយការណ៍អំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជូនក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ៤.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ០១ (មួយ) ទៅ០២ (ពីរ) រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា ០៥ (ប្រាំ) រូប និង០២ (ពីរ) ទៅ០៣ (បី) រូប ចំពោះឃុំ សង្កាត់ណាដែលមានក្រុមប្រឹក្សាចាប់ពី ០៧ (ប្រាំពីរ) រូបឡើងទៅ ឱ្យប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃក្រុមចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**ប្រការ៥.-**

ដើម្បីអនុវត្តភារកិច្ច និងការទទួលខុសត្រូវនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោត ត្រូវទទួលបាននូវធនធានសមស្រប ដែលរួមមានការបណ្ដុះបណ្ដាល ការកសាងសមត្ថភាព និងមធ្យោបាយ សម្ភារ ថវិកាសមស្រប ដែលផ្ដល់ឱ្យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**ប្រការ៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចដាក់ចេញនូវសេចក្ដីណែនាំជាក់ស្ដែងបន្ថែមទៀតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**ប្រការ៧.-**

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យស្មៀនឃុំ សង្កាត់ស្រង់ឈ្មោះប្រជាពលរដ្ឋដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ដោយផ្អែកលើឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ និងត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមកដែលទើបដល់អាយុត្រូវបោះឆ្នោត ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ដាក់ក្នុងបញ្ជីដោយឡែកពីគ្នា តាមទម្រង់ដែលកំណត់ដោយ គ.ជ.ប ហើយត្រូវថតចម្លងបញ្ជីទាំងនេះជូនលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោតរៀងរាល់ ០២ (ពីរ)ខែម្តង ។

**ប្រការ៨.-**

ក្នុងការអនុវត្តភារកិច្ច ដែលបានធ្វើប្រតិភូកម្មអំណាច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅតែទទួលខុសត្រូវរួមលើដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត និងអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ទៅលើសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោតទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយអនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

**ប្រការ៩.-**

សេចក្តីសម្រេចស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

**ថ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

សុិក ប៊ុនហុក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ២០១៦

# ប្រតិទិននៃការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦

| ការងារត្រូវអនុវត្ត | កាលបរិច្ឆេទ |
|---|---|
| ការចែកលិខិតអញ្ជើញអ្នកចុះឈ្មោះអ្នកបោះឆ្នោត | ថ្ងៃទី០១-៣១ ខែសីហា ឆ្នាំ២០១៦ |
| ការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ | ថ្ងៃទី០១.សីហា.១៦ - ០២.កុម្ភៈ.១៧ |
| ការចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ | ថ្ងៃទី០១.សីហា.១៦ - ០៩.កុម្ភៈ.១៧ |
| ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ថ្ងៃទី២៥.សីហា.១៦ - ០២.កុម្ភៈ.១៧ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះ និងការិយាល័យបោះឆ្នោត | ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ |
| ការចាប់ផ្តើមចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ |
| ការបញ្ចប់ការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ |
| ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ានឹងសេចក្តីសម្រេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈ ពេល ០៥ថ្ងៃ | ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ានឹងសេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ទូទាំងប្រទេស | ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ |
| ការប្តឹងតវ៉ា ឬប្តឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតដោយ គ.ជ.ប | ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៧ |